# ការសំភាសន៍របស់ ជិន រ៉ុម

កៈ អ្នកដែលសំភាសន៍គេជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ជិន រ៉ុម

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនដែរអ៊ុំបានអោយខ្ញុំសំភាសន៍ដែរទាកទងពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYUហាសអ៊ុំ ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណង់ចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីអោយពួកគាត់បានស្គាល់ពីប្រវត្តិដូនតានឹងផពុកម្តាយចឹងហាសអ៊ុំ ហើយនៅពេលដែរយើងសំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍នេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhitsories.byu.edu ចឹងហាសអ៊ុំ បាទចឹងសំរាប់អ៊ុំតើយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍របស់អ៊ុំទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ ដាក់ៗទៅ

កៈ បាទអ៊ុំចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍អ៊ុំនៅថ្ងៃទី19 ខែ1 ឆ្នាំ2018 ហាសអ៊ុំ ហើយធ្វើនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញហាសអ៊ុំ

ខៈ បាទនៅផ្សារដើមថ្កូវយើងនេះនឹង

កៈ បាទអ៊ុំចុះចឹងសំរាប់អ៊ុំមានឈ្មោះពេញឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំឈ្មោះដើមហី?

កៈ បាទឈ្មោះពេញហាស?

ខៈ ឈ្មោះដើមឈ្មោះរ៉ុម

កៈ ឈ្មោះរ៉ុម ណាអ៊ុំ ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខៈ ហើយឈ្មោះដែរខ្ញុំបានជួលផ្ទះគែសព្វថ្ងៃនេះគេហៅខ្ញុំតែឪអាង៉ាៗ

កៈ អូឈ្មោះឪអាង៉ាៗហាសអ៊ុំចុះកាលពីតូចមាននរណាគេហៅឈ្មោះអ៊ុំអីផ្សេងទេអ៊ុំ?

ខៈ មានតែឈ្មោះរ៉ុមមួយនឹងទេ

កៈ ឈ្មោះអីគេរ៉ុមអ៊ុំ?

ខៈ ឈ្មោះ ជិន រ៉ុម

កៈ ឈ្មោះជិន រ៉ុម ចុះអ៊ុំមានអាយុប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំអាយុ54ឆ្នាំហើយ

កៈ អ៊ុំអាយុ54ឆ្នាំចុះអ៊ុំមានដឹងថាអ៊ុំកើតនៅថ្ងៃ ខែ ឆ្នាំណាទេអ៊ុំ?

ខៈ ខ្ញុំនឹងហោស?

កៈ បាទអ៊ុំថ្ងៃខែហាស?

ខៈ ខ្ញុំមិនសូវដឹងដែរដូចថាវា បើគេអ្នកធ្វើការធ្វើអីនឹងអោយគេដឹងអាយុនឹង គេដឹងអីហាសណារួចទៅគេគិតតាមនឹងអែង គឺនៅឆ្នាំ54នេះ

កៈ ប៉ុន្តែអ៊ុំ……?

ខៈ គេជាអ្នកធ្វើការគេកើតឆ្នាំប៉ុន្មានៗគេដឹងតែខ្ញុំមិនដឹងគេបែងចែកតាមនឹងទៅ

កៈ ប៉ុន្តែអ៊ុំមានដឹងថ្ងៃ ខែថ្ងៃណាទេអ៊ុំ?

ខៈ បើថ្ងៃសៅរ៍

កៈ ចុះទីប៉ុន្មានអ៊ុំមានដឹងទេ?

ខៈ អត់ដឹងទេ

កៈ ចុះខែវិញអ៊ុំមានដឹងទេ?

ខៈ ខែមាឃ

កៈ អូខែមាឃ ចុះខែបារាំងខែអីគេដែរអ៊ុំខែ2ហីអ៊ុំ?

ខៈ ទេមើលខែមាឃធំវា ដល់ពេលដែរមាឃចឹងទៅបានប្រហ្គុន

កៈ អូមាយហើយបាន ប្រហុនណាអ៊ុំចឹងសំរាប់អ៊ុំកើតនៅឆ្នាំ1964?

ខៈ បាទប្រហែលជាប៉ុនណុងហើយ

កៈ ចុះឆ្នាំច័ន្ទគតិឆ្នាំអីគេដែរអ៊ុំ?

ខៈ ហាសឆ្នាំអីគេ?

កៈ លក្ខណៈថាឆ្នាំជូត ឆ្លូវ ខាល ថោះអីអ៊ុំមានឆ្នាំអីគេដែរអ៊ុំ អ៊ុំឆ្នាំម៉្យាញ់ រឺមួយក៏ឆ្នាំពោងអីចឹងហាសអ៊ុំឆ្នាំអីគេដែរ?

ខៈ ខ្ញុំឆ្នាំរ៉ៃក

កៈ អូអ៊ុំឆ្នាំរ៉ៃកហោស ចុះទីកន្លែងដែរអ៊ុំកើតតើអ៊ុំកើតនៅណាវិញអ៊ុំកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីចឹងហាសអ៊ុំ?

ខៈ កើតនៅភូមិចេក

កៈ នៅភូមិចេក ចុះឃុំអីគេដែរអ៊ុំ?

ខៈ ឃុំកំពុងចិនជើង

កៈ ឃុំកំពុងចិនជើង ចុះស្រុកស្អីគេដែរអ៊ុំ?

ខៈ នៅស្រុកស្ទូង

កៈ នៅស្រុកស្ទូង ខេត្ត?

ខៈ ខេត្តកំពង់ធំយើងនេះនឹង

កៈ បាទអ៊ុំចុះអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានបងប្អូនវាមាន4នាក់ ប៉ុន្តែក្រោយទៅវាឡើង5នាក់

កៈ អូម៉េចចឹងអ៊ុំ?

ខៈ ដោយសារតែម្តាយរបស់ខ្ញុំបានស្លាប់តាំងពីពេលដែរខ្ញុំចេះដើរតេកតាក់ចឹងហាស បើនិយាយទៅស្លាប់តាំងពីយួនចូលមកម្លេ៉ស
ហោពីមុនយួនចូលមកម្លេ៉សស្លាប់តាំងពីមុនពលពតទៀតនឹងនិយាយទៅនឹង

កៈ ប៉ុន្តែបងប្អូនរបស់អ៊ុំមាន5នាក់

ខៈ មាន4នាក់ហើយឪពុករបស់ខ្ញុំបានយកចាប់ពីជំនាន់ពលពតនោះ
គាត់បានយកម៉ែរបស់ខ្ញុំ

កៈ ដល់ពេលនេះបានម្នាក់ទៀតទៅ

ខៈ ពេលដែរគាត់យកនឹងបាន5នាក់ទៀត

កៈ អូចឹងបានបងប្អូន5នាក់ទៀតចឹងមានន័យថា9នាក់?

ខៈ អានឹងដូចថាបងប្អូនបង្កើតដោយសារតែឪពុកតែមួយហាស

កៈ បាទចឹងវាឡើង9នាក់ហើយណអ៊ុំ?

ខៈ បាទអានឹងបានត្រូវតែបើឪពុកមុនមានតែ4នាក់ទេ ហើយក្រោយ5នាក់ទៀតវាបាន9

កៈ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនរបស់គាត់

កៈ បើកូនរបស់គាត់4នាក់មុនហាស តើអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនទី3

កៈ អ៊ុំជាកូនទី3ណា ចុះបងប្អូនរបស់អ៊ុំមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានស្រី2នាក់ ហើយប្រុស2នាក់

កៈ មានស្រី2 ប្រុស2 អ៊ុំជាកូនទី3ណា
ចុះអ៊ុំមានចងចាំបងប្អូនរបស់អ៊ុំមានឈ្មោះអីគេខ្លះអ៊ុំមានស្គាល់ឈ្មោះគាត់ទេបងៗ
រឺមួយក៏ប្អូនរបស់អ៊ុំហាស?

ខៈ ចឹមិនស្គាល់

កៈ មានឈ្មោះអីគេដែរបងបង្អស់ហាស?

ខៈ បងបង្អស់មានឈ្មោះបងចេន

កៈ ឈ្មោះអីគេចេនហោសអ៊ុំ?

ខ៖ ឈ្មោះជិន ចេននឹងហាស

ក៖ ឈ្មោះបងទី2?

ខ៖ ចុះបើដាក់តែត្រកូលៀឪពុកមួយនឹងអែងនឹង

ក៖ ចុះបងទី2មានឈ្មោះអីគេដែរ?

ខ៖ ជិនចេន ជិន ប៉ា

ក៖ នឹងបងទី2ណាអ៊ុំ ចុះទី3អ៊ុំ ចុះទី4វិញ

ខ៖ ទី4មានឈ្មោះជិន ណា

ក៖ ជិន ណាណាអ៊ុំ?

ខ៖ បាទអានឹងពៅគេហើយនឹង

ក៖
ចុះអ៊ុំមានចងចាំសាច់រឿងអីកាលពីអ៊ុំនៅជាមួយពួកគាត់រឺក៏អនុស្សាវរីយ៍អីជាមួយគ្នាហាស
អ៊ុំ?

ខ៖ ថាម៉េចដែរ?

ក៖ ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលនៅជាមួយគ្នាមានលេងឡឹកបាយឡ រឺមួយក៏លេង
ផ្ទាត់កៅស៊ូអីចឹងហាសអ៊ុំ?

ខ៖ អារឿងនឹងវាមានច្រើនណាស់
អារឿងលេងនឹងវាមានច្រើនណាស់ជួនកាលលេងក្របីជល់គ្នាអីណាអីណី
ពេលដែរទៅឃ្វាលគោហាសណា លេងពួនទៅ មុជទឹកតាមទឹកអូរអីចឹងទៅ

ក៖ អូចឹងបាទអ៊ុំ?

ខ៖ មានបងប្អូនអ្នកស្រុកភូមិ5-
6នាក់លេងតាមស្រុកភូមិតែឥឡូវចេះតែលេងសើចចឹងទៅណា

ក៖ ដើរទៅស្រែអីជាមួយគ្នាទៅណាអ៊ុំ?

ខ៖ បាទនឹងហើយលេង

ក៖ ទៅលេងនៅស្រែរត់លេងជាមួយគ្នា

ខ៖ នឹងហើយលេងទាំងងស់នឹង

ក៖ ចុះអ៊ុំគិតថាតាំងពីក្មេងហាសតើអ៊ុំចូលចិត្តលេងអីគេជាមួយបងប្អូនរបស់អ៊ុំដែរ?

ខ៖ ខ្ញុំធ្វើស្រែ

ក៖ ចូលចិត្តធ្វើស្រែជាមួយបងប្អូនរបស់អ៊ុំណាអ៊ុំ?

ខ៖ បាទធ្វើស្រែចិញ្ចឹមប្អូន ចិញ្ចឹមក្មួយអីចឹងទៅ

ក៖ បាទអ៊ុំចុះបងប្អូនរបស់អ៊ុំសព្វថ្ងៃនឹងគាត់រស់នៅណាដែរអ៊ុំ?

ខ៖ គាត់នឹងបងប្អូនរបស់ខ្ញុំនៅច្រើនកន្លែងណា

ក៖ ដូចជាមាន4នាក់មុននឹងហាសអ៊ុំ?

ខ៖ អុ4នាក់មុននឹងហោស

ក៖ បាទ4នាក់មុននឹង

ខ៖ បងរបស់ខ្ញុំគាត់នៅភ្នំពេញនឹងគាត់នៅខាងក្តាន់2

ក៖ ចុះគាត់នឹងគាត់ធ្វើអីគេដែរអ៊ុំបងធំរបស់អ៊ុំហាស?

ខ៖ កាលពីមុននឹងគាត់និយាយអោយចំតួទៅគាត់មកនៅភ្នំពេញនឹងយូរហើយណា

ក៖ គាត់ធ្វើអីអ៊ុំ?

ខ៖ គាត់ដើររើសអេតចាយ

ក៖ អូនៅក្តាន់2នឹងទៅហោសអ៊ុំ?

ខ៖ ពីមុនដំបូងតែដល់ពេលយូរៗទៅគាត់បានតែមួយបាយហូបអីទេណា
ហើយដល់ពេលណុងទៅគាត់បានទាក់ទង់គេរកការងារធ្វើការបើកឡាន

ក៖ អូគាត់បើកឡានអោយគេណាអ៊ុំ?

ខ៖ បាទដល់ពេលដែរទៅៗមុនដំបូងគេគ្រាន់តែអោយបាយ
នឹងអោយដេករស់នៅលើគេចឹងហាសណា គ្រាន់តែគេថាអោយបាយទឹកស្អីៗ
ហើយអោយលុយចាយបន្តិចបន្តួចអីចឹងហាស

ក៖ អូគាត់ស្នាក់នៅលើគេ?

ខ៖ នឹងហើយឧបម៉ាថាគេអោយលុយខ្លះចាយចឹងហាស4000-5000ចាយចឹងហាសណា
គាត់យកតំរះ ធ្វើឡានធ្វើអី
ទៅបានជាគាត់ចេះបើកតិចៗទៅក៏គាត់បានបើកឡានអោយថៅកែនឹងតែម្តងនឹងទៅ

ក៖ ចុះបងទី2របស់គាត់ធ្វើអីគេទៅ ហើយគាត់នៅណាដែរទៅអ៊ុំ?

ខ៖ បងទី2ហាស បងទី2នៅស្វងនឹងអែងនៅជិតម៉ែឪនឹង

ក៖ ចុះគាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ គាត់លក់បន្លែ គាត់លក់ត្រកួន ដូចស្អីនឹងទៅ និយាយរួមទៅដូចថាបន្លែគ្រប់មុខទៅណា
ដូចជាទ្រប់ តាំងពីអីចឹងហាសណា យកទៅលក់តាមផ្សារ
ឧបម៉ាថាយើងទិញពីតាមកូនក្មេង នឹងតាមភូមិតិចតួច
ហើយយើងយកទៅលក់ដើម្បីចំណេញក្បាលកាក់ហាសណា

ក. អូលក្ខណះថាយើងទិញតាមផ្សារដើម្បីយកទៅលក់តាមភូមិនឹងហោសអ៊ុំ?

ខ៖ ទេទិញតាមភូមិយកទៅលក់តាមផ្សារវិញ

ក៖ អូចឹងវិញហោសអ៊ុំ?

ខ៖ គ្រាន់តែថាវាបានចំណេញ

ក៖ ចំណេញបន្តិចបន្តួចទៅ

ខ៖ នឹងហើយគ្រាន់តែថាវាបានចំណេញបន្តិចបន្តួចៗទៅនឹង

ក៖ ចុះប្អូនពៅរបស់អ៊ុំគាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ ប្អូនពៅនឹង ប្អូនពៅគាត់ធ្វើស្រែដែរនឹង

ក៖ គាត់ធ្វើស្រែនឹងដែរចុះគាត់នៅណាវិញទៅអ៊ុំ គាត់នៅកំពង់ធំនឹងដែរ?

ខ៖ គាត់នៅស្វែងជិតម៉ែឪនឹង

ក៖ ប៉ុន្តែអ៊ុំមកលក់លាស?

ខ៖ បាទសំរាប់អ៊ុំលក់លាសនឹងអែង

ក៖ ចុះម្តាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំដែរស្លាប់នឹងអី?

ក៖ បាទអ៊ុំម្តាយរបស់អ៊ុំហាស?

ខ៖ ម្តាយដែរបានស្លាប់នឹងគាត់មានឈ្មោះ រ៉ាន់

ក៖ ម្តាយរបស់អ៊ុំគាត់ឈ្មោះរ៉ាន់ ណាអ៊ុំ ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានដឹងអត់អ៊ុំ?

ខ. អត់ដឹងទេ

ក៖ ចុះគាត់អាយុប៉ុន្មានអ៊ុំមានដឹងទេអ៊ុំ?

ខ៖ នរណាគេដែរ?

ក៖ ម្តាយរបស់អ៊ុំដែរស្លាប់នឹងហាស?

ខ៖ ខ្ញុំអត់ដឹងដែរនឹង

ក៖ ចុះកាលពីគាត់ស្លាប់នឹងអ៊ុំមានដឹងថាគាត់ស្លាប់នៅឆ្នាំណាអត់អ៊ុំ?

ខ៖
គាត់កាលពីគាត់ស្លាប់នឹងខ្ញុំនៅតូចដែរខ្ញុំមិនដូរដឹងដែរបើសិនជាលោកឪពុករបស់ខ្ញុំប្រហែលជាខ្ញុំនឹងអាចដឹងថាគាត់ស្លាប់ពីឆ្នាំប៉ុន្មានៗចឹងហាសណា

ក៖ សំរាប់ម្តាយអ៊ុំអត់ដឹងទេ?

ខ៖ ចុះបើខ្ញុំនៅចេះរត់តេះតាក់ៗនឹងគាត់បានស្លាប់ចោលនឹង

ក៖ ចុះអ៊ុំមានដឹងថាម្តាយរបស់អ៊ុំគាត់កើតនៅណាទេអ៊ុំ?

ខ៖ គាត់កើតនៅណា?

ក. ដូចថាគាត់នៅស្នួងនឹងដែរ?

ខ៖ នឹងហើយដូចថាគាត់កើតខុសគ្នាឪពុករបស់ខ្ញុំបានម៉ែរបស់ខ្ញុំនឹងនៅភូមិតែមួយនឹង

ក៖ អូនៅភូមិតែមួយណា ចុះឪពុករបស់អ៊ុំមានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំមានឈ្មោះជិន

ក៖ ចុះឈ្មោះស្អីគេជិនទៅអ៊ុំ ត្រកូលរបស់គាត់ហាស?

ខ. ត្រកូលឈ្មោះចាន់ ជិន

ក៖ គាត់ឈ្មោះចាន់ ជិន ចុះគាត់អាយុប៉ុន្មានដែរហើយអ៊ុំ?

ខ៖ សព្វថ្ងៃនេះគាត់ចូលអាយុ83ឆ្នាំហើយគាត់ចាស់ហើយ

ក៖ ប៉ុន្តែគាត់នៅរស់តាហ៎អ៊ុំ?

ខ៖ នឹងហើយគ្រាន់តែថាគាត់បាននាំកូនចៅទៅវត្តទៅវ៉ាអី
ទាំងកូនប្រសារទាំងកូនបង្កើតអីគ្រាន់ឌុបម៉ូតូឌុបអីទៅ
យកគាត់ទៅវត្តទាំងម៉ែទាំងពុកនឹងអែង

ក៖ ចុះគាត់អាយុ83ឆ្នាំចុះថ្ងៃខែឆ្នាំកំណើតរបស់គាត់អ៊ុំមានដឹងអត់អ៊ុំ
ដឹងថាគាត់កើតនៅថ្ងៃខែឆ្នាំណាអីចឹងហាសអ៊ុំ?
ខ៖ ខ្ញុំអត់ដឹងទេ

ក៖ អាយុ83គាត់ដក់ទៅគាត់កើតនៅឆ្នាំ1935អ៊ុំ?

ខ៖ នឹងហើយ

ក៖ ឪពុករបស់អ៊ុំហាស ចុះគាត់កើតនៅណាវិញអ៊ុំ?

ខ៖ គាត់កើតនៅណុងអែងនឹង

ក. គាត់កើតនៅណុងតែម្តងហោសអ៊ុំ?

ខ៖ បាទគាត់កើតនៅភូមិចេកនឹងអែង

ក៖ ចុះឪពុករបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំនឹងហោស

ក៖ បាទឪពុករបស់អ៊ុំហាស?

ខ៖ ឪពុករបស់ខ្ញុំធ្វើស្រែនឹងហាស

ក៖
ចឹងមានន័យថាគាត់ធ្វើស្រែតាំងពីក្មេងរហូតមកដល់ឥឡូវគាត់នៅតែធ្វើស្រែដដែរណអ៊ុំ?

ខ៖ សព្វថ្ងៃនឹងគាត់ធ្វើបានតិចតួចសំរាប់តែកូនចៅទេ
គាត់នៅចំណាស់ទៅហើយគាត់មានទៅធ្វើស្អីកើតទៀតគ្រាន់តែកូនចៅក្មួយអីចិញ្ចឹមគាត់តា ទៅវត្តទៅវ៉ាអីកូនក្មេងឱបទៅៗ

ក៖ ចុះឪបុករបស់អ៊ុំគាត់ជាមនុស្សបែបណាដែរអ៊ុំគាត់ជាមនុស្សស្លូត រឺមួយក៏កាចដែរអ៊ុំ?

ខ៖ ដូចថាគាត់ស្លូតក៏មិនស្លូត ហើយបើថាគាត់កាចក៏មិនកាច បើគាត់កាចគឺគាត់.......

ក៖ គាត់កាចតាមកាលៈទេសៈ?

ខ៖ នឹងហើយគាត់កាចតាមកាលៈទេសៈដែរគេធ្វើអោយគាត់កាចគាត់កាច
បើគ្មានសាច់រឿងកាចក៏គាត់ស្លូតដែរនឹង

ក៖ ចុះម្តាយរបស់អ៊ុំគាត់រកស៊ីធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ អូការងារគាត់ច្រើនណាស់ មានដាំជីដាំអី មានឃ្លោកត្រឡាចអីទៅព្រឹកឡើង
អានឹងនិយាយពីគាត់នៅក្មេងទេណា

ក៖ បាទចឹងមានន័យថាគាត់ធ្វើអាជីវកម្មនៅផ្ទះនឹងដែរ?

ខ៖ បាទគាត់ធ្វើអាជីវកម្មនៅផ្ទះដែរមានដាំបន្លែ ដាំត្រកួនដាំននោងអីៗទៅ
នរណាគេទៅក៏ទិញ2-3ទៅក៏បានលុយនឹងអែងទិញម្ហូទិញស្លាអីទៅ
ទិញនុំចំណីតិចតួចទៅណានិយាយអោយឆាប់ចប់ទៅមនុស្សឃ្លានទិញស៊ីទិញមួយពាន់ទៅពីរពាន់អីទៅប្រាំរយអីទៅនៅតាមស្រុកស្រែហាសណា

ក៖ ចុះគាត់ជាមនុស្សបែបណាដែរអ៊ុំគាត់ស្លូត រឺមួយក៏កាច?

ខ៖ គាត់ស្លូតទេ

កៈ ចុះអ៊ុំមានចងចាំសាច់រឿងអីចាមួយពួកគាត់អត់ជាមួយម្តាយឪពុករបស់អ៊ុំអត់ ដូចថាគាត់ធ្លាប់ប្រើទៅណា ហើយគាត់អោយធ្វើអីចឹងហាស?

ខៈ អូអារឿងប្រើវាប្រើហើយជូនកាលវាមានតែតមាត់ជាមួយពួកគាត់ដែរ

កៈ ប៉ុន្តែអ៊ុំមានចងចាំទៅស្រែជាមួយពួកគាត់អីអត់អ៊ុំ?

ខៈ អត់អត់ដឹងថាធ្វើស្រែធ្វើអី

កៈ ចុះឪពុករបស់អ៊ុំគាត់មានធ្លាប់ពីប្រវត្តិគាត់កាលពីគាត់នៅក្មេងអីទេអ៊ុំ?

ខៈ កាលពីក្មេងខ្ញុំអត់ដឹងដែរនឹង

កៈ អូគាត់អត់ដែរប្រាប់អីទេណាអ៊ុំ?

ខៈ អត់ទេ

កៈ
ចុះម្តាយរបស់អ៊ុំគាត់មានធ្លាប់ប្រាប់បីប្រវត្តិគាត់កាលពីគាត់នៅក្មេងទៅប្រាប់អ៊ុំអត់ថាគាត់ធ្លាប់ធ្វើអីគេខ្លះចឹងហាសអ៊ុំ?

ខៈ អត់ទេ

កៈ ហើយគាត់ម្តាយរបស់អ៊ុំដោយសារស្អីៗគាត់ដែរប្រាប់ទេ?

ខៈ អត់ដែរប្រាប់ទេ

កៈ ចុះអ៊ុំមានចងចាំជីដូនជីតាខាងម្តាយរបស់អ៊ុំអត់អ៊ុំ?

ខៈ អត់ទេ

កៈ មានឈ្មោះអីៗក៏អ៊ុំអត់ចាំដែរណាអ៊ុំ?

ខៈ តែបើឈ្មោះខ្ញុំដឹង

កៈ ចឹងយាយតាខាងម្តាតរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះចាន់

កៈ ចាន់នឹងឈ្មោះយាយរឺមួយក៏តា?

ខ៖ ជីដូនឈ្មោះយាយរស់

ក៖ ចឹងឈ្មោះយាយ រស់ តាចាន់?

ខ៖ នឹងហើយយាយតារបស់ខ្ញុំ

ក៖ អ៊ុំមានដឹងថាគាត់កើតនៅណាដែរទេអ៊ុំ?

ខ៖ គាត់កើតនៅណុងអែងនឹង

ក៖ គាត់កើតនៅណុងដែរណអ៊ុំ?

ខ៖ គាត់នៅស្រុកតែមួយនឹងអែង

ក៖ ចុះយាយតាខាងឪពុកវិញអ៊ុំមានស្គាល់ឈ្មោះគាត់ទេ?

ខ៖ អត់ស្គាល់ទេ

ក៖ អ៊ុំអត់ស្គាល់ទេណអ៊ុំ?

ខ៖ អត់ស្គាល់ទេមិនដឹងថាគាត់មានឈ្មោះអី

ក៖ អូអ៊ុំកើតមកមិនទាន់មែន?

ខ៖ កាលណុងកាលពីចាស់ៗពីដើម

ក៖ អ៊ុំមកនៅភ្នំពេញនឹងយូនៅអ៊ុំ?

ខ៖ ខ្ញុំមកនៅនិយាយរួមទៅវាចូល17-18ឆ្នាំហើយ

ក៖ អូ18ឆ្នាំហើយណ
ចុះអ៊ុំមានបងប្អូនរឺមួយលស់សាច់ញ្ញាតិណាដែររស់នៅក្រៅពីប្រទេសកម្ពុជាទេអ៊ុំ
ដូចជាវៀតណាម ថៃ ឡាវចឹងហាស?

ខ៖ គ្មានទេ

ក៖ កូនក្មួយអីក៏អត់មានដែរ?

ខ៖ អូមានទើបតែទៅៗ
អាប្អូនដែរថាមាន5នាក់នឹងហាសអានោះវាទី3វាទើបតែទៅមិនមែនវាទៅតែអែងទេវាទៅចាមួយម៉ែក្មេកវាទៅថៃឥឡូវនៅថៃនឹងហាស

ក៖ គាត់ធ្វើអីគេដែរនៅណុងហោសអ៊ំ?

ខ៖ គេធ្វើអីៗនឹង

ក៖ គេធ្វើការងារនៅថៃនឹងទៅ?

ខ៖ នឹងហើយគេធ្វើការងារកំប៉េកកំប៉ុកតិចតួចនៅថៃនឹងអែង

ក៖ ចុះភរិយារបស់អ៊ំកាត់មានឈ្មោះអីគេដែរអ៊ំ?

ខ៖ ភរិយាមុននឹងអី?

ក៖ អត់ទេប្រពន្ធរបស់អ៊ំគាត់មានឈ្មោះអីគេដែរ

ខ៖ ប្រពន្ធរាល់ថ្ងៃនឹងអី?

ក៖ បាទប្រពន្ធរាល់ថ្ងៃរបស់អ៊ំហាស?

ខ៖ ប្រពន្ធរាល់ថ្ងៃមានឈ្មោះប៉ូ

ក៖ ឈ្មោះប៉ូចឹងមានន័យថាអ៊ំមានប្រពន្ធ2ណាអ៊ំ?

ខ៖ បាទមានប្រពន្ធ2ប៉ុន្តែប្រពន្ធមុនវាស្លាប់បានកូន3នាក់

ក៖ ប៉ុន្តែអ៊ំមកយកប្រពន្ធក្រោយនេះបានកូនប៉ុន្មានទៅអ៊ំ?

ខ៖ អត់មានទេ

ក៖ អត់ទាន់មានទេណាអ៊ំ?

ខ៖ អត់មានទទេតែម្តងនឹង

ក៖
ចុះអ៊ំអាចប្រាប់ខ្ញុំបានទេថាអ៊ំបានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់អ៊ំបានទេដូចជារៀបអាពាហ៍ពិពាហ៍នៅពេលណាថ្ងៃខែឆ្នាំណាអីចឹងហាសអ៊ំ?

ខ៖ នៅពេលដែររៀបចំនឹងហាស?

ក៖ ពេលដែរអ៊ុំបានការហាស?

ខ៖ នៅឆ្នាំ1984

ក៖  នៅឆ្នាំ1984?

ខ.  នឹងហើយថ្ងៃខែនឹងវា1984 និយាយពីការប្រពន្ធហី?

ក៖ បាទនិយាយការប្រពន្ធ?

ខ៖ ការប្រពន្ធនឹងវា84

ក៖ ការនៅឆ្នាំ1984?

ខ៖ ការបានកូន3ហើយប្រពន្ធបានស្លាប់ចោល

ក៖ ចុះថ្ងៃខែអ៊ុំចាំទេ?

ខ៖ ថ្ងៃខែប្រពន្ធនឹងមែន?

ក៖ ថ្ងៃខែដែរអ៊ុំការនឹងហាស?

ខ៖ អត់អត់ដឹងដឹងតែនៅឆ្នាំ84 ដូចថា81 82 ,83 ,84ហាសណា

ក៖
ចុះអាពាហ៍ពិពាហ៍របស់អ៊ុំតើអ៊ុំជាអ្នករៀបចំដោយខ្លួនអែងរឺមួយក៏ឪពុកម្ដាយជាអ្នករៀបចំអោយដែរអ៊ុំ?

ខ៖ ម៉ែឪជាអ្នករៀបចំនឹង

ក៖ អូឪពុកម្ដាយរបស់អ៊ុំគាត់ជាអ្នករៀបចំអោយហោសអ៊ុំ
ចុះកាលពីអ៊ុំបានទៅរៀបការជាមួយនឹងអ៊ុំស្រីនឹងដូចជាអ៊ុំមានជាជំនូនអោយទៅអ៊ុំស្រីអត់?

ខ៖ អោយបើយើងមិនអោយធ្វើម៉េចបានការ ឧបម៉ាថាកាលពីជំនាន់ណុងលុយវាថ្លៃហាស

ក៖ អ៊ុំអោយប៉ុន្មានដែរអ៊ុំ?

ខ៖ បើនិយាយពីលុយដែរឥឡូវនឹងយើងថាប្រហែលជា50ម៉ឺនទៅចុះ

កៈ លុយ50ម៉ឺនច្រើនហាសណាអ៊ុំកាលពីជំនាន់ណុង?

ខៈ លុយច្រើនដែរនឹងថា30ម៉ឺទៅចុះអើរអាណុងស៊ីសងទៅលើម៉ែឪទៅចុះ

កៈ កាលណុងមាស1ជី10ម៉ឺនថ្លៃហាសណាអ៊ុំ?

ខៈ បាទថា20-30ម៉ឺនទៅចុះ

កៈ ចុះអ៊ុំគិតថាអ៊ុំចេះភាសាខ្មែររឺក៏អានបានល្អប៉ុណ្ណាដែរអ៊ុំ អ៊ុំមានធ្លាប់បានរៀនទេអ៊ុំ?

ខៈ ខ្ញុំធ្លាប់រៀនតែខ្មែរនឹង

កៈ អ៊ុំរៀនខ្មែរបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំរៀនកាលណុងវាបានថ្នាក់ទី5

កៈ អ៊ុំបានរៀននៅថ្នាក់ទី5ប៉ុន្តែពេលណុងនៅបឋមសិក្សាតាហីអ៊ុំ?

ខៈ ខ្ញុំវារវល់បឋមសិក្សាដូចយើងសព្វថ្ងៃនឹងចឹងហាស

កៈ ក្មេងៗនឹងអ៊ុំហាស ប៉ុន្តែសាលាអ៊ុំអ៊ុំស្គាល់ឈ្មោះទេសាលារបស់អ៊ុំមានចាំឈ្មោះអត់?

ខៈ សាលាប្រូ

កៈ សាលាប្រូហោសអ៊ុំ?

ខៈ នៅខេត្តនឹងឈ្មោះសាលាប្រូ

កៈ នៅខេត្តកំពង់នឹង?

ខ.  នៅស្ទួងនឹង

កៈ នៅស្ទួងនឹងហោសអ៊ុំ?

ខៈ ខេត្តកំពត់ធំនៅឆ្ងាយហាសពីស្រុកខ្ញុំមកនឹងហាសមកទីរួមខេត្តវា50គីឡូ

កៈ ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាថៃភាសាវៀតណាមអីអ៊ុំចេះអត់?

ខៈ អត់ចេះភាសាយួនតិច

កៈ ចេះភាសាយួនតិបណាអ៊ុំ?

ខ៖ ចេះថាណាំចាំ បាចាំ

ក៖ ចុះអ៊ុំធ្លប់មានមិត្តភក្តិស្និទ្ធិស្នាលណាដែរធំធាត់មកជាមួយគ្នាអត់អ៊ុំ?

ខ៖ ពួកម៉ាក់ជិតស្និទ្ធិនឹងមែន?

ក៖ បាទលក្ខណះថាមិត្តភក្តិជិតស្និទ្ធិហាស?

ខ៖ សព្វថ្ងៃនឹងហាស?

ក៖ ទាំងសព្វថ្ងៃទាំងកាលពីតូចមកអ៊ុំមានអត់?

ខ៖ មានតាមាននៅស្រុកនឹងហោស បើថានៅភ្នំពេញនឹងគ្មានទេ

ក៖ ប៉ុន្តែមានឈ្មោះអីគេខ្លះអ៊ុំអាចប្រាប់ឈ្មោះ2-3នាក់ក៏បានចឹងហាស?

ខ៖ ឈ្មោះដែរធ្លាប់បានដើរលេងតិចតួចនឹងហី?

ក៖ បាទឈ្មោះពួកគាត់ហាស?

ខ៖ ឈ្មោះនឿន

ក៖ ឈ្មោះនឿន ឈ្មោះអីគេទៀតអ៊ុំ?

ខ៖ ឈ្មោះឃី

ក. ឈ្មោះឃីចុះអ៊ុំមានចងចាំសាច់រឿងអីដែរអ៊ុំគិតថាបានដើរលេងជាមួយគ្នា
កាលពីនៅតូចៗហាសណាអ៊ុំមានទេ ដូចជាធ្លាប់ទៅលេងទឹកជាមួយគ្នា
រឺក៏ដើរលេងស្រែជាមួយគ្នាអីចឹងហាសណា?

ខ៖ បើថាអារឿងណុងវាមានដែរបើថាលេងចេះតែលេងទៅលក្ខណះថាឃ្វាលគោ
ឃ្វាលក្របីអីចឹងទៅណា

ក៖ ចុះអ៊ុំមានធ្លប់ទៅធ្វើការនៅវាលស្រែ រឺចំការអត់អ៊ុំ?

ខ៖ អត់មានទេចំការមានតែវាលស្រែ

ក៖ មានតែស្រែនឹងអ៊ុំធ្លាប់ទៅធ្វើណាអ៊ុំ?

ខ៖ នឹងធ្លាប់ធ្វើ

ក៖ ចុះអ៊ុំមានធ្លាប់បង្កើតមុខរបរអាជីវកម្មអីទេលក្ខណៈថាលក់ដូរ រឺមួយក៏ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូកអីចឹងហាសអ៊ុំ?

ខ៖ ធ្លាប់ដែរតែវាគ្រាន់តែមិនបាននៅយូរពេលដែរធំល្មមមើលទៅរៀងខូះខាតបញ្ចេញទៅលក់ចោល វាគ្រាន់តែថាមិនបានយូរឆ្នាំអីៗនឹងគេហាណា

ក៖ អូចឹងហោសអ៊ុំ?

ខ៖ នឹងហើយគ្រាន់ថាវាមិនសូវមានលុយលក់ចេញទៅគ្រាន់វាបានទិញនេះទិញនោះហូបទៅ

ក៖ ចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរទៅអ៊ុំ?

ខ៖ មានការផ្លាស់ប្តូរអីមានតែលក់លាស ហើយនឹងធ្វើសំណង់

ក៖ អូលក់លាស នឹងធ្វើសំណង់ណអ៊ុំ និយាយរួមទៅវាមួយរស់ៗណអ៊ុំ?

ខ៖ និងហើយវាធ្វើសំណង់មួយរស់ៗនឹង

ក៖ ចុះអ៊ុំគិតថាម្ហូបអីគេដែរអ៊ុំចូលចិត្តជាងគេដែរអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវអ៊ុំនៅតែចូលចិត្តចឹងហាសអ៊ុំ?

ខ៖ ឆា ចៀន ស្ងោ

ក៖ បាទលក្ខណៈថាឆា ចៀន ស្ងោ រឺមួយក៏ស្លម្ជូ រឺក៏សំលកអីចឹងហាស?

ខ៖ ភាច្រើនមានតែស្ងោ

ក៖ ស្ងោអ៊ុំចូលចិត្តណអ៊ុំ?

ខ៖ លក្ខណៈថាស្ងោមាន់ ស្ងោទាអីចឹងទៅ រឺក៏ស្ងោត្រីភាគច្រើនទៅណា បើនិយាយពីអាំងដុតវិញយូរៗម្តងទេពីព្រោះតែខ្ញុំចូលចិត្តតែបានទឹកហុត

កៈ
ចុះល្បែងកំសាន្តអីគេដែរអ៊ុំចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ឥឡូវដែរអ៊ុំគិតថាចូលចិត្ត ដែរលេងហោសអ៊ុំ?

ខៈ ចូលចិត្តលេងអានេះតិចទៅលេងអានោះតិចទៅ

កៈ លក្ខណះថាល្បែងប្រចាប្រិយ៍អីដូចជាបោះអង្គុញ លាក់កន្សែង ទាញព្រាត់ ចោលឈូអីចឹងហាសអ៊ុំចូលចិត្តទេ?

ខៈ នឹងហើយដូចចោលឈូង លេងងង្គុញ លេងអីដូចថាខែចេត្រចូលឆ្នាំ ដូចថានាំគ្នាដើរទៅលេងនៅវត្ត ហើយក៏បោះឈូងទៅ ហើយលេងអង្គុញចឹងទៅ

កៈ
ចុះអ៊ុំមានចងចាំបទចំរៀងណាដែរអ៊ុំគិតថាបានរៀនច្រៀងតាំងពីក្មេងមករហូតមកដល់ឥឡូវដែរអ៊ុំនៅតែចាំហាស?

ខៈ គ្មានទេ

កៈ អត់មានទេណាអ៊ុំ តើអ៊ុំចូលចិត្តស្តាប់បទចំរៀងអត់អ៊ុំ?

ខៈ ចូលចិត្តដែរតា លឺស្ញូរគេចាក់បាសចាក់អីចឹងទៅ ពីមុនខ្ញុំមានបាសដែរតា
ហើយខ្ញុំបានផ្ញើរទៅម្តាយមីង
ហើយម្តាយមីងបានដាក់ទៅក្រោមគ្រែទៅហើយគាត់ដាក់តាមរទេះ

កៈ ប៉ុន្តែដូចជាបទអីគេដែរអ៊ុំចូលចិត្តលក្ខណះជាបទសម័យ
រឺមួយក៏ជាបទបុរាណអីចឹងហាសណាអ៊ុំ?

ខៈ បទបើនិយាយអោយសព្វថ្ងៃទៅវាចូលបទកន្រ្ទឹម

កៈ បទកន្រ្ទឹមណាអ៊ុំ?

ខៈ អត់ទេបទសីនស៊ីសសាម៉ុត

កៈ អូបទសីនស៊ីសាម៉ុត
ចុះអ៊ុំមានបងប្អូនរបស់អ៊ុំណាមួយរឺក៏សាច់ញ្ញាតិណាមួយចេះលេងឧបករណ៍ភ្លេងអត់អ៊ុំ?

ខៈ ថាម៉េចភ្លេងខ្មែរម៉េច?

កៈ ដូចថាភ្លេងខ្មែរ ភ្លេងអីរ៉ុបអីចឹងហាស ដូចថាភ្លេងខ្មែរអាវៃគោះភ្លេង វៃឃឹមអីចឹងហាស?

ខៈ ដូចទ្រអីនឹង

កៈ បាទដូចជាទ្រអីចឹងហាសអុំ?

ខៈ មានតាប៉ុន្តែនៅស្ទួងហោស

កៈ ប៉ុន្តែសាច់ញ្ញាតិរឺក៏កូនក្មួយ បងប្អូនដែរអុំ?

ខៈ ដូចជាអ្នកជិតខាងអីចឹងហាសដូចថាអ្នករាប់អានគ្នា
ដូចថាយើងមានរវល់ទៅក៏ហៅគេមកលេងអីចឹងទៅណា

កៈ ចុះផ្ទះរបស់អុំមានលក្ខណៈបែបណាទាំងពីក្មេងរហូតមកដល់ពេលនេះហាសអុំ
កាលពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវផ្ទះយ៉ាងម៉េចផ្ទះស្នាក់នៅហាសអុំ?

ខៈ ផ្ទះស្នាក់នៅនឹងហោសកាលពីមុនឪពុករបស់ខ្ញុំគាត់លក់អស់ហើយ
តែពុកខ្ញុំគាត់បានធ្វើថ្មី

កៈ បាទអុំប៉ុន្តែកាលពិមុនដូចជាផ្ទះអីគេអុំដូចជាផ្ទះឈើ រឺក៏ផ្ទះថ្ម?

ខៈ កាលពីមុននឹងផ្ទះគ្រឿង ផ្ទះគ្រឿងប៉ុន្តែឈើ ផ្ទះក្រោយនេះឈើដែរ ឈើប៉ុន្តែប្រក់ប៉េត្រូ
ពួកអាក្របហាមៗយើងនឹងហាស

កៈ ចុះផ្ទះរបស់ធ្វើនឹងនរណាគេជាអ្នកធ្វើគិតថាឪពុករបស់អុំជាអ្នកធ្វើ
រឺមួយក៏ជួលគេធ្វើកាលធ្វើផ្ទះរបស់អុំហាស?

ខៈ ជួលគេខ្លះ ហើយធ្វើខ្លួនយើងខ្លះដែរ ដូចថាយើងចេះអីៗនឹងទៅ

កៈ យើងចេះអី យើងធ្វើនឹងទៅ?

ខៈ ដូចថាធ្វើពីដែកឈូស

កៈ
ប៉ុន្តែអុំមានដឹងថាឧបករណ៍សំរាប់សាងសងផ្ទះនឹងគេមានឧបករណ៍អីគេខ្លះដែរអុំមានដឹង
អត់?

ខៈ មានចេះតែមានហើយបន្តិចបន្តួច

កៈ មានអីគេខ្លះដែរអ៊ុំដែរអ៊ុំអាចរៀបរាប់តិចបានទេអ៊ុំមានដូចជាដែកឈូសអីចឹងហាសអ៊ុំ?

ខៈ មានដូចជារណា ស្អីគេអាប្រដាប់ដែរគេស្វាននេះគេហៅអីគេ?

កៈ គេហៅរណា មានដែកស្វាន
ចុះអ៊ុំគិតថាអ៊ុំមានជំនាញអីដែរអ៊ុំគិតថាអ៊ុំចេះពីក្រុមគ្រួសាររឺមួយក៏អ៊ុំចេះដោយខ្លួនអែងអត់អ៊ុំ?

ខៈ ថាម៉េចទៅ?

កៈ ដូចថាជាជំនាញអីមួយដែរអ៊ុំគិតថាអ៊ុំចេះដូចជាវេញល្អី ក្ងរក
រឺមួយក៏ជំនាញអីដែរអ៊ុំគិតថាចេះស្ទាត់ជំនាញដែរហាសអ៊ុំ
រឺមួយក៏លក្ខណៈចេះលក់លាសដែរស្ទាត់ជំនាញអីចឹងហាស?

ខៈ ខ្ញុំចេះតែលក់ដូរអីនឹងហាស

កៈ អ៊ុំចូលចិត្តលក់លាស លក់ដូរណាអ៊ុំ?

ខៈ លក់លាសនឹងហើយ

កៈ
ចុះអ៊ុំអាចប្រាប់បានទេថាតើពេលណាដែរអ៊ុំគិតថាលំបាកជាងគេនៅក្នុងជីវិតរបស់អ៊ុំហាស
តើអ៊ុំអាចប្រាប់បានទេ?

ខៈ រឿងពិបាកវាពិបាកហើយសព្វថ្ងៃនឹងវាមានទៅស្រួលអីប៉ុន្មានទេ

កៈ អូបាទអ៊ុំមានការពិបាកច្រើនណាអ៊ុំ?

ខៈ អារឿងពិបាកវាពិបាកហើយ អានេះទាំតែយើងវាមានធូរធា
អានោះបានគេថាលែងលពិបាកហើយ

កៈ បាទឥឡូវនៅតែក្រចឹងទៅ?

ខៈ ចុះបើយើងក្រលក់តែលាស មិនដូចជាកូនគេអ្នកមានអីណាគេទៅមួយភ្លេតឡានៗ

កៈ ចុះអ៊ុំឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរអ៊ុំ?

ខៈ ពិបាកច្រើនណារឿងពិបាកនឹង

កះ ចុះពេលណាដែរដែលអ៊ុំគិតថាជាពេលដែរសប្បាយហាសអ៊ុំ?

ខះ ដូចជាអារឿងសប្បាយនឹងវាមានភាគតិចដែរធ្វើអោយសប្បាយ

កះ ដូចជាពេលដែរអ៊ុំការ
រឺមួយក៏ពេលដែរអ៊ុំមានកូនចៅហាសដែរធ្វើអោយអ៊ុំសប្បាយដែរអ៊ុំ?

ខះ អារឿងនឹងវាសប្បាយដែរតែសប្បាយភាគតិច មិនចេះតែសប្បាយរហូតណា

កះ បាទអ៊ុំ ចុះអ៊ុំធ្លាប់មានក្ដីស្រម៉ៃអីគេទេថាអ៊ុំតាំងពីក្មេងអ៊ុំចង់ធ្វើអីគេចឹងហាស?

ខះ ថាម៉េចដែរ?

ក. អ៊ុំមានធ្លាប់មានក្ដីស្រម៉ៃថាពេលដែរអ៊ុំធំឡើងអ៊ុំចង់ធ្វើជាគ្រូពេទ្យ
រឺមួយក៏គ្រូបង្រៀនអីចឹងហាសអ៊ុំមានអត់អ៊ុំ?

ខះ នៅខ្ញុំប្រលងជាប់គ្រូដែរគេប្រុងអោយធ្វើគ្រូដែរ
តែខ្ញុំមានរវល់ជាប់មើលគោមើលក្របីក៏ខ្ញុំឈប់តែម្ដងទៅ
បើខ្ញុំរៀនតទៅមុខអីខ្ញុំបានធ្វើគ្រូតទីមុខទៀតបាត់ ដូចថាយើងវាជាប់មើលគោ ក្របី

កះ ចុះបើចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗរបស់អ៊ុំ
គិតថាអ៊ុំចង់ផ្ដែផ្ដាំអីទៅគាត់ដើម្បីអោយគាត់អាចខំប្រឹងរៀន
រឺមួយក៏អាចអោយគាត់ខំប្រឹងរៀនធ្វើការងារអីល្អចឹងហាសអ៊ុំ
ដើម្បីអោយគាត់មានជីវភាពល្អជាងនឹងអីចឹងហាស
បើចង់អោយអ៊ុំផ្ដែផ្ដាំតើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរអ៊ុំ?

ខះ ផ្ដែផ្ដាំអោយកូនក្មួយដែរនៅនឹងអោយគាត់ខំប្រឹងរៀនសូត្រអីទៅ
តែធំឡើងយើងចេះដឹងទៅ

កះ ចឹងមានអីទៀតអត់អ៊ុំ?

ខះ អត់ទេ

កះ
ចឹងអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍នឹងបានពិភាក្សាជាមួយអ៊ុំហាសអ៊ុំបាទ៕៕៕